សហភាពអឺរ៉ុប  កម្មវិធីស្បៀងអាហារ

# បច្ចេកទេសដាំដំណាំបន្លែ



## មាតិកា

១ ដំណាំត្រកួន និងដំណាំផ្ទី

២ ដំណាំស្ពៃចង្កឹះ ស្ពៃខៀវ ខាត់ណាដើម ឆៃថាវ

៣ ដំណាំសណ្តែកកួរ និងត្រសក់ចំណារ

៤ ដំណាំត្រប់ និងប៉េងប៉ោះ

៥ សមាសភាពចង្រៃ និងវិធានការការពារ

៦ លក្ខណៈបច្ចេកទេស នៃដំណាំបន្លែ









## ១~ការជ្រើសរើសពូជ

- ជ្រើសរើសគ្រាប់ពូជ ដែលមានអត្រាដំណុះខ្ពស់ពី៨៥-៩០ភាគរយ
- ពូជដែលផ្តល់ទិន្នផលខ្ពស់ ធននឹងអាកាសធាតុ សត្វល្អិត នឹងជម្ងឺ
- ពេញនិយម នឹងមានតំលៃលើទីផ្សារ ស្គាល់ពីប្រវត្តិពូជច្បាស់លាស់

## ២~ការរៀបចំដី

- ភ្ជួរ ឬកាប់ត្រលប់ដីអោយបាន ២ទៅ៣ដង - ជំរៅពី២៥សម-៣០សម
- រាស់បំបែកដីអោយរាបស្មើ ហាលដីអោយស្ងួត សំអាតស្មៅអោយបានស្អាតល្អ

## ៣~ ការសាប និងបណ្តុះកូន

- ហាលគ្រាប់ពូជក្រោមកំដៅថ្ងៃក្តៅល្មមរយៈពេលពី១-២ម៉ោង
- នៅរដូវវស្សា ត្រូវត្រាំគ្រាប់ពូជក្នុងទឹកក្តៅឧណ្ហៗ ពី២០-៣០នាទី រួចទុកអោយត្រជាក់ រយៈពេលពី២-៣នាទី ទើបយកគ្រាប់ពូជទៅផ្អាប់ រុំនឹងក្រណាត់អោយជិត រក្សានៅកន្លែងហប់ មានកំដៅរយៈពេលពី ២យប់ ដើម្បីអោយគ្រាប់ឆាប់ដុះ ។

## ៤~ ការដាំ និងស្ទូងកូន

- លើករង: កំពស់ ២០-២៥សម x ទទឹងរង ១០០-១២០សម x បណ្តោយតាមស្ថានភាពដី
- ប្រើជី: ជីធម្មជាតិចំនួន៣០០គក និងជី១៥-១៥-១៥ ចំនួន១គក ក្នុងផ្ទៃដី១០០ម$^2$ (ត្រប់)

  ជីធម្មជាតិចំនួន៤០០-៥០០គក និងជី១៥-១៥-១៥ ចំនួន១គក ក្នុងផ្ទៃដី១០០ម$^2$ (ប៉េងប៉ោះ)
- ត្រូវដាំកូនដំណាំនៅពេលរសៀល ដើម្បីកាត់បន្ថយការប៉ះពាល់កំដៅថ្ងៃខ្លាំង
- ចន្លោះគុម្ពពី ៧០-៨០សម និងចន្លោះជួរពី១០០-១២០សម (ត្រប់)
- ចន្លោះគុម្ពពី៥០សម-៦០សម និងចន្លោះជួរពី៧០សម-៨០សម (ប៉េងប៉ោះ)

## ៥~ ការថែទាំកូនក្រោយពេលដាំ

- ស្រោចទឹកកូនដំណាំ អោយសើមល្មមក្រោយពេលដាំ
- គ្របរង ឬគុម្ពដំណាំភ្លាមបន្ទាប់ពីដាំកូនរួចក្នុងរយៈពេលយ៉ាងយូរ២ថ្ងៃ
- ក្រោយពេលដាំរយៈពេល១០-១៥ថ្ងៃ ត្រូវសំអាតស្មៅ ជ្រោយដី ពូនគល់ និងបំប៉នជី ព្រមទាំងដោតចំណារ គួរកាត់ស្លឹកចាស់ៗ ដែលទុំនៅផ្នែកក្រោមចោល

**ការប្រើប្រាស់ជី** (តាមសភាពដី និងការលូតលាស់របស់ដំណាំ)

លើកទី១: អ៊ុយរ៉េ ៥០០ក្រាម ដោយលាយទឹក ឬកប់ជុំវិញគល់ ក្នុងផ្ទៃដី ១០០ម$^2$

លើកទី២: អ៊ុយរ៉េ ៥០០ក្រាម នឹងជី១៥-១៥-១៥ ចំនួន៦០០ក្រាម ក្នុងផ្ទៃដី ១០០ម$^2$ ក្រោយពេលដាំ ពី២០-២៥ថ្ងៃ លាយចូលគ្នា ដោយកប់ជុំវិញគល់ គម្លាតពីគល់ប្រមាណ១០-១៥សម

## ៦~ ការប្រមូលផល

- ក្រោយរយៈពេលដាំពី៥០-៧៥ថ្ងៃ យើងអាចចាប់ផ្តើមប្រមូលផលលើកទី១
- ប្រមូលផលនៅពេលព្រឹក ឬពេលរសៀល ដោយប្រើឧបករណ៍ និងសម្ភារៈស្អាត នឹងគ្មានមេរោគ
- រក្សាផលិតផលទុកនៅក្រោមម្លប់ កន្លែងត្រជាក់ល្អ សីតុណ្ហភាពពី១៥-២៨អង្សាសេ
- ដឹកជញ្ជូនផលិតផលនៅពេលព្រឹក ដោយវេចខ្ចប់អោយបានល្អ ដើម្បីរក្សាគុណភាព

## ៧~ ការជ្រើសរើស និងទុកដាក់ពូជដំណាំ

- ជ្រើសរើសផ្លែដែលថ្លោសល្អ គ្មានជម្ងឺ នឹងស្នាមសត្វល្អិតបំផ្លាញ ទុកផ្លែអោយទុំសព្វល្អ
- បេះផ្លែដោយកាត់យកផ្នែកកណ្តាលនៃផ្លែ (ត្រប់) រក្សាទុករយៈពេល២យប់ ច្របាច់យកគ្រាប់ បន្ទាប់មកលាងសំអាតគ្រាប់អោយស្អាតល្អ ដោយប្រើស្បៃ ទើបយកគ្រាប់ ដំណាំទៅហាលសំងួតអោយស្ងួតរយៈពេល២-៣ថ្ងៃ ទុកអោយត្រជាក់ ទើបច្រកក្នុងកែវ ឬដប ដែលស្រុះទឹកក្តៅ ស្ងួតល្អ ដោយបិទអោយជិត នឹងរក្សាទុកនៅក្នុងម្លប់ *(ពូជបង្កាត់មិនអាចទុកពូជបាន)*



**ដំណាំ ត្រប់ ប៉េងប៉ោះ**

# ដំណាំសណ្តែកគួរ ត្រសក់ចំណារ





## ១_ការជ្រើសរើសពូជ

- ជ្រើសរើសគ្រាប់ពូជ ដែលមានអត្រាដំណុះខ្ពស់ពី៨៥-៩០ភាគរយ
- ពូជដែលផ្តល់ទិន្នផលខ្ពស់ ធននឹងអាកាសធាតុ សត្វល្អិត និងជម្ងឺ
- ពេញនិយម និងមានតំលៃលើទីផ្សារ ស្គាល់ពីប្រវត្តិពូជច្បាស់លាស់

## ២_ការរៀបចំដី

- ភ្ជួរ ឬកាប់ត្រលប់ដីអោយបាន ២ទៅ៣ដង - ជំរៅពី២៥សម-៣០សម
- រាស់បំបែកដីអោយរាបស្មើ ហាលដីអោយស្ងួត សំអាតស្មៅអោយបានស្អាតល្អ
- លើករងដែលមានទទឹង១០០-១២០សម កំពស់១៥សម-២០សម (រដូវប្រាំង) និងពី ២៥-៣០សម (រដូវវស្សា) និងបណ្តោយរងទៅតាមស្ថានភាពដី
- ដាក់ជីធម្មជាតិ ពី២០០-៤០០គក្រ និងជី១៥-១៥-១៥ ចំនួន១គក្រ/១០០ម$^{២}$

## ៣_ការដាំគ្រាប់

- ហាលគ្រាប់ពូជក្រោមកំដៅថ្ងៃក្តៅល្មម រយះពេលពី១-២ម៉ោង
- ដាំដោយកប់គ្រាប់ក្នុងជំរៅ២-៣សម ចំនួន២-៣គ្រាប់ ក្នុង១រណ្តៅ
- ដាំក្នុងចន្លោះគុម្ពពី៤០-៥០សម និងចន្លោះជួរពី៦០-៨០សម

## ៤_ការថែទាំក្រោយពេលដាំ

- ស្រោចទឹកអោយសើមល្មមលើរងដំណាំក្រោយពេលដាំ ២ដង ក្នុង១ថ្ងៃ (ព្រឹក ល្ងាច)
- សំអាតស្មៅ ជ្រោយដីអោយបានល្អ និងពូនគល់នៅពេលដែលដំណាំមានស្លឹកពី៣-៤សន្លឹក
- ក្រោយពេលដាំរយះពេលពី១៤-២១ថ្ងៃ ត្រូវដោតចំណារ ឬដាក់ទ្រើង អោយបានកំពស់ពី ២ម-២,៥០ម។
- កាត់ស្លឹកក្រោមដែលចាស់ ឬមានជម្ងឺ និងខ្នែងដែលលូតលាស់មិនល្អចោល។

### ការប្រើប្រាស់ជីគីមី

- **លើកទី១:** ក្រោយពេលដាំ ពី៧-១២ថ្ងៃ ដាក់ជីអ៊ុយរ៉េ ចំនួន៥០០ក្រាម ក្នុងផ្ទៃដី ១០០ម$^{២}$ លាយទឹកស្រោច ឬកប់ជុំវិញគល់
- **លើកទី២:** ក្រោយពេលដាំ ពី២០-២៥ថ្ងៃ ដាក់ជីអ៊ុយរ៉េ ៥០០ក្រាម និងជី ១៥-១៥-១៥ ចំនួន៦០០ក្រាម/១០០ម$^{២}$ ដោយកប់ជុំវិញគល់ គម្លាតពីគល់ប្រមាណ ១០សម-១៥សម

## ៥_ការប្រមូលផល

- ក្រោយរយះពេលដាំពី៥០-៥៥ថ្ងៃ យើងអាចចាប់ផ្តើមប្រមូលផលលើកទី១
- ប្រមូលផលនៅពេលព្រឹក ឬពេលរសៀល ដោយប្រើឧបករណ៍ និងសម្ភារៈស្អាត និងគ្មានមេរោគ
- រក្សាផលិតផលទុកនៅក្រោមម្លប់ កន្លែងត្រជាក់ល្អ សីតុណ្ហភាពពី១៥-២៨អង្សាសេ
- ដឹកជញ្ជូនផលិតផលនៅពេលព្រឹក ដោយវេចខ្ចប់អោយបានល្អ ដើម្បីរក្សាគុណភាព

## ៦_ការជ្រើសរើស និងទុកដាក់ពូជដំណាំ

- ជ្រើសរើសយកផ្លែដែលថ្លោសល្អ គ្មានជម្ងឺ និងស្នាមសត្វល្អិតបំផ្លាញ
- ទុកផ្លែអោយទុំសព្វល្អ បេះផ្លែ ដោយកាត់យកផ្នែកកណ្តាលនៃផ្លែ(ត្រសក់) ដោយកោស លាងសំអាតគ្រាប់អោយស្អាតល្អ និងហាលអោយស្ងួត
- កាត់យកកួរ ហាលសំងួតអោយស្ងួតល្អរយះពេល២-៣ថ្ងៃ
- ទុកអោយត្រជាក់ ទើបច្រកក្នុងកែវ ឬដប ដែលស្រុះនឹងទឹកក្តៅ ស្ងួតល្អ ដោយបិទអោយជិត និងរក្សាទុកនៅក្នុងម្លប់។